# សិលាចារឹកប្រាសាទកំបុត ខេត្តព្រះវិហារ

ប្រាសាទកំបុត មានទីតាំងស្ថិតនៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ដែលស្ថិតនៅក្បែរច្រកទ្វារព្រំដែនកម្ពុជា-ថៃ (ច្រកអានសេះ)។ ប្រាសាទនេះ កសាងឡើងនៅទីតាំងខ្ពស់មួយ មានប្រាង្គចំនួន ១ ដែលស្ថានភាពប្រាសាទនាពេលសព្វថ្ងៃនៅមានទ្រង់ទ្រាយនៅឡើយ ។ តើសិលាចារឹកប្រាសាទកំបុត មានខ្លឹមសារ និងអត្ថន័យយ៉ាងដូចម្ដេចខ្លះ?

សិលាចារឹកប្រាសាទកំបុត ចារឹកនៅលើបង្ខុះមេទ្វារទាំងពីរ។ មេទ្វារម្ខាងមានចារឹកអក្សរចំនួន ៤ បន្ទាត់។ ប៉ុន្តែយើងមិនបានយកមកអាននោះទេ ដោយសារតែសព្វថ្ងៃឥដ្ឋនៅផ្នែកដំបូលដែលបាក់រលំ និងដំបូកដីផងនោះ យើងមិនអាចធ្វើសំណៅផ្តិតឱ្យបានគ្រប់ជ្រុងជ្រោយនៃផ្ទាំងចារឹកទាំងមូលឡើយ។ ចំណែកមេទ្វារម្ខាងទៀតស្ថិតនៅខាងមុខ ហើយមានចារឹកអក្សរចំនួន ១៦ បន្ទាត់ ដែលយើងលើកយកមកបង្ហាញក្នុងអត្ថបទនេះ។ ក្នុងនោះ ដោយសារតែអក្សរនៅចារឹកនៅលើមេទ្វារនេះចារឹកអក្សររាក់ពេក នាំឱ្យផ្នែកខ្លះនៃពាក្យចារឹកនេះបានរលុបបាត់មួយចំនួន។ ផ្នែកដំបូងរបស់សិលាចារឹកប្រាសាទកំបុត បានពណ៌នាឱ្យយើងដឹងអំពីកាលបរិច្ឆេទ ពោល គឺមហាសករាជឆ្នាំ៨៩២ ដែលត្រូវនឹងឆ្នាំ៩៧០នៃគ្រិស្តសករាជ ១២កើត ខែបុស្ស ថ្ងៃពុធ ហើយកាលបរិច្ឆេទនេះត្រូវនឹងរជ្ជកាលព្រះបាទស្រីជយវម៌្ម (ទី៥) (គ.ស.៩៦៨ ដល់ ១០០០)។

សិលាចារឹកនេះ ពោលរៀបរាប់អំពី អធិការបតិទេវស្ថានព្រះសិវបាទម្នាក់មានគោរម្យងារជា “**ស្តេងអញអាចារ្យ**”។ ប្រភពក្នុងសិលាចារឹកនេះបានបង្ហាញថា “*ស្តេងអញអាចារ្យខ្លោញគ្នំសិវបាទ គឺជាចៅអាវាស ឬអធិការបតិរបស់ទេវស្ថានសិវបាទ*” ដែលទំនងសំដៅដល់ “សិវបាទបូព៌” ឬសព្វថ្ងៃខ្មែរយើងស្គាល់ថាជា “**ប្រាសាទនាគបួស**” នោះឯង។ ប្រភពសិលាចារឹកប្រាសាទនាគបួកបានបញ្ជាក់ឱ្យដឹងថា “ប្រាសាទនាគបួស មាននាមដើមថា “**សិវបាទបូព៌**” (សិវបាទខាងកើត) (K.341) ឬពេលខ្លះហៅត្រឹមតែ “**សិវបាទ**” (K.348) តែប៉ុណ្ណោះ។ ព្រមជាមួយគ្នានេះ សិលាចារឹកប្រាសាទកំបុតបានបង្ហាញថា ព្រះតេជគុណស្តេងអញអាចារ្យខ្លោញគ្នំសិវបាទ បានទៅទេវស្ថានមួយមានឈ្មោះថា “**ព្រះកម្រតេងអញសិវលិង្គ**” ស្ថិតនៅឯកទ្រូបូរ ដែលជាទីតាំង និងឈ្មោះដើមរបស់ទេវស្ថាននេះ។ ប្រាសាទកំបុតសាងឡើងសម្រាប់តម្កល់ព្រះសិវលិង្គ (ព្រះកម្រតេងអញសិវលិង្គ) ហើយទេវស្ថាននេះស្ថិតនៅក្នុងក្រុងកទ្រូបូរ (វិមាន ឬក្រុងរបស់ព្រះកទ្រ ឬព្រះឥសូរ)។ ព្រះ

អត្ថបទដោយ៖ កំ វណ្ណារ៉ា

តេជគុណស្តេងអញអាចារ្យខ្លោញភ្នំសិវបាទ បានរៀបចំរណ្តាប់ផ្សេងៗដល់ទេវស្ថាន ដែលក្នុងនោះមានដូចជា តម្រួច (តម្រួត) ពលព្រះជាកម្លាំងស្នូលក្នុងការបម្រើ និងការពារទេវស្ថាន។ នៅចុងបញ្ចប់របស់សិលាចារឹកនេះ ជាពាក្យបណ្តាសា និងពាក្យជូនពរដល់បណ្តាជនទាំងឡាយណាដែលថែរក្សាទ្រព្យសម្បត្តិទេវស្ថាន។

**អត្ថបទចារឹក**

១. ៨៩២ ឝក ទ្វាទឝិកេតិ បុឞ្យ វុទ្ធវារ ឝុស្តេងឝ៏អញ
២. អាចាយ៌្យខ្លោញវ្នំឝិវបាទ និវន្ធវុវតតម្រាចខ្ញុំវ្រះ
៣. កម្រតេងឝ៏អញឝិវលិង្គអាយឝិកទ្រេបូរឝុថ្វេ ....
៤. ខ្ញុំផោង៌មឝិស្តេងឝ៏អញអាចាយ៌្យអាយឝិគុហាលយ..បិ ប្រេ
៥. ត វ្រះកំម្រតេងឝ៏អញឝិវលិង្គ ៙ មឝិតិ ..........តវ្រះក
៦. ម្រតេងឝ៏អញអាយឝិកំប្វូលវ្នំមឝិដៅបិវ្យាសង ..........
៧. ឝុដៅវមាសិចាងម្វាយឝិតិថ្វេឱយគជាសម្វាយឝិ
៨. គោបិវ្រះម្វាយឝិខ្នុបិជ្សិវ្រះម្វាយឝិចន្សាកិយោ......វ្រះ
៩. កម្រតេងឝ៏អញតគគ្តិចតុម្នាំស.........................បិជា
១០. យជ្ញដេវ្យរម្វាយឝិខេមហាងសម្វាយឝិចំដាំ................
១១. តិអ្នកិជារិចញ្ចូលិតថ្ងៃអាចិតិអ្នកិដោ .........សំ
១២. គណាឝុវ្រះកម្រតេង៏អញអាយឝិឝិវចាង...........
១៣. យ៌្យតស្តេង៏អញអាចាយ៌្យតខ្លោញវ្នំ..........អាយឝិក
១៤. ទ្រេបូរគុសនៅគេតវ្វំថ្ងៃយកល្បជាតពោះហនេះហតនៅតតិ
១៥. ពោះនរកាត....ប្រតិមហាពេវវគេតម្យាឝ៏ថ្ងៃយនេះ
១៦. កល្បជាតពោះហនេះហគេមានស្វគ៌ឝុពៅង៌យឝិក្លេយ។

**សេចក្តីប្រែ**

(១-៣) មហាសករាជ៨៩២ ១២កើត ខែបុស្ស ថ្ងៃពុធ ស្តេងអញអាចារ្យ ជាខ្លោញភ្នំ (អធិការបតិទេវស្ថាន) សិវបាទ បាននិពន្ធ (រៀបចំ) តម្រួច (តម្រួត) អ្នកបម្រើព្រះ (ពលព្រះ) ថ្វាយដល់ព្រះកម្រតាងអញសិវលិង្គនៅឯកទ្របូរ និងបានធ្វើ...អ្នកបម្រើផង ដែលស្តេងអញអាចារ្យនៅឯគុហាល័យ....ដើម្បីបង្គាប់ប្រើដល់ព្រះកម្រតាងអញសិវលិង្គ។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

(៩-១២) គឺ ..ដល់ព្រះកម្រតាងអញស្ថិតនៅឯកំពូលភ្នំ ដែលបានដាវ ..និងដាវមាសមួយបាទ បានធ្វើនិងប្រគល់ឱ្យគទាស (ខ្ទះ) មួយ ទោប (សម្លៀកបំពាក់ជាក្រណាត់កន្ទប) វ៉ះមួយ ខ្ទបប្សិរ វ៉ះមួយ ចន្ទ្យាក (សម្លៀកបំពាក់)..យៅ ព្រះកម្រតាងអញជ័សក្តិចតុម៌ាស (៤ខែ) ...សម្រាប់ដើម្បីជាការធ្វើពិធីយជ្ញចំនួន ២ ជេ (កញ្ជើ) ក្នុងមួយខែ មហានស (អ្នកចម្អិនអាហារ) ម្នាក់សម្រាប់ជារណ្ដាប់តង្វាយ ..អ្នកដែលទា (ទទួល) ចញ្ជូល (ប្រេង) ដទៃទៀត មិនអាចដើម្បីទៅ ...សំគណ (រួមផ្សំបញ្ចូល) និងព្រះកម្រតាងអញសិវបាទ ...ស្តេងអញអាចារ្យ ជាខ្លោញភ្នំ (អធិការបតិទេវស្ថាន)...នៅឯកទ្រូបូរដាច់ខាត។

(១៤-១៦) នៅអម្បាលជនទាំងឡាយណាដែលមិនបានធ្វើកល្បណា (អំណោយតង្វាយទាន ឬបំផ្លាញ) ដល់ទេវស្ថាននេះ គេធ្លាក់ទៅក្នុងប្រតិមហាពៅរវនរក។ ជនណាដែលបានធ្វើកល្បណា (អំណោយតង្វាយទាន) និងការធ្វើឱ្យចម្រើនរុងរឿងសម្រាប់ទេវស្ថានក្នុងទីនេះ ជននោះទៅកាន់ស្ថានសួគ៌ និងសេចក្តីចម្រើនក្រៃលែងឡើង។

ជារួមមក សិលាចារឹកប្រាសាទកំពុត ខេត្តព្រះវិហារ បានផ្តល់ព័ត៌មានអំពីមន្ត្រីម្នាក់ដែលបានទៅធ្វើអំណោយដល់ទេវស្ថានមួយមានឈ្មោះថា “**ព្រះកម្រតេងអញសិវលិង្គ**” ស្ថិតនៅឯកទ្រូបូរ ដែលជាទីតាំង និងឈ្មោះដើមរបស់ប្រាសាទកំពុតនេះផ្ទាល់តែម្តង។ ផ្អែកទៅតាមសិលាចារឹកនេះ នាំឱ្យយើងដឹងថា កាលពីដើមមកគេបានតម្កល់ព្រះសិវលិង្គមួយនៅក្នុងប្រាសាទ ដែលជាតឹកតាងអាចបញ្ជាក់ថា ប្រាសាទនេះជាប្រាសាទព្រហ្មញ្ញសាសនា ក្នុងលទ្ធិសៃវនិយម។

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ១៖ ប្រាសាទកំបុត ខេត្តព្រះវិហារ



រូបលេខ២៖ មេទ្វារចារឹកខាងត្បូង នៃប្រាសាទកំបុត ខេត្តព្រះវិហារ

អត្ថបទដោយ៖ កំ វណ្ណាក់



រូបលេខ៣៖ មេទ្វារចារឹកខាងជើង នៃប្រាសាទកំបុត ខេត្តព្រះវិហារ



រូបលេខ៤៖ មេទ្វារចារឹកខាងជើង នៃប្រាសាទកំបុត ខេត្តព្រះវិហារ

អត្ថបទដោយ៖ កំ វណ្ណារ៉



រូបលេខ៥៖ សំណៅផ្តិតមេទ្វារចារឹកខាងជើង នៃប្រាសាទកំបុត
ផ្តិតដោយ៖ កំ វណ្ណាក់ និង ហឿន លាងហួន